អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## សេចក្តីថ្លែងការណ៍របស់ សហព្រះរាជអាជ្ញាអន្តរជាតិ ទាក់ទងនឹងសំណុំរឿងលេខ ០០៣

សហព្រះរាជអាជ្ញាអន្តរជាតិ លោក អាន់ឌ្រូ ឃេលី ធ្វើសេចក្តីប្រកាសជាសាធារណៈនេះដោយអនុលោមតាម វិធាន ៥៤ នៃវិធានផ្ទៃក្នុងរបស់ អវតក ដើម្បីធានាដល់តម្រូវការក្នុងការផ្តល់ព័ត៌មានដល់សាធារណៈជនអំពី វិវឌ្ឍនភាពនៃដំណើរការរបស់ អវតក និងដោយឡែក ពាក់ព័ន្ធទៅនឹងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើ សំណុំរឿងលេខ ០០៣ របស់សហព្រះរាជអាជ្ញាអន្តរជាតិ ។ ក្នុងការផ្តល់ព័ត៌មាននេះ ផលប្រយោជន៍របស់ ជនរងគ្រោះ និងសាក្សី, សិទ្ធិក្នុងការការពារខ្លួនរបស់ជនសង្ស័យ និងតម្រូវការផ្នែកស៊ើបអង្កេត ត្រូវបានយកមក គិតពិចារណាដោយទៅស្របតាមតម្រូវការនៃ វិធានផ្ទៃក្នុង ។

អនុលោមតាមសេចក្តីបង្គាប់របស់អង្គបុរេជំនុំជម្រះ នៅថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០០៩ សហព្រះរាជអាជ្ញាអន្តរជាតិ បានដាក់ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរចំនួនពីរជូនទៅសហចៅក្រមស៊ើបអង្កេត ដើម្បីឲ្យបើកកិច្ចស៊ើបសួរ លើឧក្រិដ្ឋកម្មផ្សេងៗដែលមាននៅក្នុងសំណុំរឿងលេខ០០៣ និង ០០៤ ។ ដីកាសន្និដ្ឋានទាំងនេះ មានឈ្មោះ ជនសង្ស័យសរុបចំនួនប្រាំ(០៥)នាក់ ដែលសហព្រះរាជអាជ្ញាជឿជាក់ថាត្រូវទទួលខុសត្រូវចំពោះឧក្រិដ្ឋកម្មនានា ដែលបានលើកឡើងចោទប្រកាន់ និងដែលស្ថិតនៅក្រោមយុត្តាធិការរបស់ អវតក ។ តាមវិធានផ្ទៃក្នុងសម្រាប់ អវតក តម្រូវឲ្យ សហចៅក្រមស៊ើបអង្កេត ធ្វើការស៊ើបសួរទៅលើឧក្រិដ្ឋកម្មនានាដែលបានលើកឡើងចោទ ប្រកាន់នៅក្នុងដីកាសន្និដ្ឋានទាំងនេះ ។

ដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើសំណុំរឿងលេខ០០៣ បានលើកឡើងចោទប្រកាន់ពីឧក្រិដ្ឋកម្មនានា រួមមាន៖ ការធ្វើមនុស្សឃាត ការសម្លាប់រង្គាល ការធ្វើទារុណកម្ម ការដាក់ក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់ ការធ្វើឲ្យទៅជាទាសករ ការធ្វើទុក្ខបុកម្នេញ និងអំពើអមនុស្សធម៌ដទៃទៀត ។ បើត្រូវបានបង្ហាញសក្ខីកម្ម អំពើទាំងនេះនឹងបង្កើតបានជា ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ អំពើបំពារបំពានយ៉ាងធ្ងន់ធ្ងរទៅលើអនុសញ្ញាទី ក្រុងហ្សឺណែវ និង ការរំលោភលើ ក្រមព្រហ្មទណ្ឌកម្ពុជា ឆ្នាំ១៩៥៦ ។

ឧក្រិដ្ឋកម្មនានាតម្រូវឲ្យធ្វើស៊ើបសួរជាផ្នែកនៃសំណុំរឿងលេខ០០៣ បានកើតឡើងនៅតាមទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋនានាជាច្រើនដែលគ្របដណ្តប់ដោយសំណុំរឿងលេខ០០២ ដែលរួមមាន៖ មន្ទីរសន្តិសុខស- ២១, ការដ្ឋានសាងសង់ព្រលានយន្តហោះកំពង់ឆ្នាំង, ការបោសសម្អាតភូមិភាគបូព៌ា ភូមិភាគកណ្តាល

និងភូមិភាគឧត្តរថ្មី ហើយនិងការលុកលុយចូលក្នុងប្រទេសវៀតណាម ក៏ដូចជាទីតាំងឧក្រិដ្ឋកម្ម និងព្រឹត្តិការណ៍ឧក្រិដ្ឋកម្មថ្មីៗនានា ដូចខាងក្រោមនេះ៖

(១) មន្ទីរសន្តិសុខស-២២ នៅក្នុងតំបន់ភ្នំពេញ។
(២) មន្ទីរសន្តិសុខវត្តអង្គតាញ្ញាណនៅក្នុងខេត្តកំពង់សោម។
(៣) ការដ្ឋានពលកម្មដោយបង្ខំកន្លែងយកថ្មនៅស្ទឹងហាវនៅក្នុងខេត្តកំពង់សោម។
(៤) ការចាប់ចង ជនជាតិបរទេសនៅក្បែរតំបន់ឆ្នេរសមុទ្រកម្ពុជា និងការដាក់ពួកគេនៅក្នុងមន្ទីរឃុំឃាំងដោយខុសច្បាប់, ការបញ្ជូនទៅស-២១ ឬ ការសម្លាប់។ និង
(៥) មន្ទីរសន្តិសុខនានាដែលបានដំណើរការប្រព្រឹត្តទៅនៅក្នុងខេត្តរតនៈគីរី ។

កាលពីថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១១ ការិយាល័យសហព្រះរាជអាជ្ញា បានទទួលសេចក្តីជូនដំណឹងថា សហចៅក្រមស៊ើបអង្កេតបានបញ្ចប់កិច្ចស៊ើបសួរលើសំណុំរឿងលេខ០០៣ ។ ដោយបានពិនិត្យឡើងវិញលើសំណុំរឿងយ៉ាងហ្មត់ចត់ សហព្រះរាជអាជ្ញាអន្តរជាតិ មានបំណងស្នើសុំឲ្យបំពេញកិច្ចស៊ើបសួរ បន្ថែមទៀតពាក់ព័ន្ធទៅនឹងក្រិដ្ឋកម្មនានាដែលបានលើកឡើងចោទប្រកាន់ ក្នុងរយៈពេលយ៉ាងយូរ ១៥ថ្ងៃ ដូចដែលបានកំណត់នៅក្នុងវិធាន ៦៦.១ នៃវិធានផ្ទៃក្នុងសម្រាប់ អវតក ។ ក្នុងចំណោមអ្វីៗផ្សេងទៀតជាច្រើន សហព្រះរាជអាជ្ញាអន្តរជាតិនឹងស្នើសុំឲ្យ សហចៅក្រមស៊ើបអង្កេត៖

១. កោះហៅ និងសួរចម្លើយជនសង្ស័យនានាដែលមានឈ្មោះនៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើសំណុំរឿងលេខ០០៣ និង កំណត់អត្តសញ្ញាណអ្នកទាំងនោះថាពួកគេស្ថិតនៅក្រោមការស៊ើបសួរ ។

២. ស្តាប់ចម្លើយបុគ្គលបន្ថែមថ្មីដែលរហូតមកដល់ពេលនេះត្រូវបានកំណត់អត្តសញ្ញាណថាជាសាក្សីដែលមានសក្តានុពល ។

៣. ស្តាប់ចម្លើយ ឬស្តាប់ចម្លើយសារជាថ្មីឡើងវិញ ចំពោះសាក្សីនានាដែលត្រូវបានកំណត់អត្តសញ្ញាណនៅក្នុងសំណុំរឿងលេខ០០២ ដោយផ្តោតទៅលើការលើកឡើងចោទប្រកាន់ជាក់លាក់នានាដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរលើសំណុំរឿងលេខ០០៣ ។

៤. ពិនិត្យបន្ថែមទៀតទៅលើទីតាំងឧក្រិដ្ឋកម្មនានា (រួមទាំងការស្រាវជ្រាវរកទីកន្លែងកប់សាកសពរួម) ។

៥. ដាក់ភស្តុតាងបន្ថែមចូលទៅក្នុងសំណុំរឿង រួមទាំងការផ្ទេរភស្តុតាងបន្ថែមទៀតពីសំណុំរឿងលេខ០០២ ទៅក្នុងសំណុំរឿងលេខ០០៣ ។ និង

៦. ស៊ើបសួរបន្ថែមទៀតអំពីការចូលរួមរបស់ជនសង្ស័យនៅក្នុងសំណុំរឿងលេខ០០៣ នៅក្នុងឧក្រិដ្ឋកម្មនានា រួមទាំងការបញ្ជូនពួកអ្នកទោសដែលស្ថិតនៅក្រោមការត្រួតត្រារបស់ពួកគេឲ្យទៅកាន់មន្ទីរស-២១, ការទទួលបានរបស់ជនសង្ស័យនូវ"ចម្លើយសារភាព"ដែលស្រង់បានពីពួកអ្នកជាប់គុកដែលត្រូវបានគេសម្លាប់នៅមន្ទីរស-២១ និងការចូលរួមរបស់ពួកគេនៅក្នុងការចាប់ខ្លួនបន្តបន្ទាប់មកទៀត។

សហព្រះរាជអាជ្ញាអន្តរជាតិ នឹងស្នើសុំនូវវិធានការណ៍ទាំងនេះ ដោយសារសហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា ឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់ដូចដែលមាននៅក្នុងដីកាសន្និដ្ឋានបញ្ជូនរឿងឲ្យស៊ើបសួរមិនទាន់ត្រូវបានធ្វើការស៊ើបអង្កេតពេញលេញទេ ។ សហព្រះរាជអាជ្ញាអន្តរជាតិមានកាតព្វកិច្ចតាមផ្លូវច្បាប់តាមវិធានផ្ទៃក្នុង និងច្បាប់ស្តីពីការបង្កើត អវតក ក្នុងការកំណត់អត្តសញ្ញាណនិងស្នើសុំឲ្យបំពេញរាល់កិច្ចស៊ើបសួរទាំងអស់ដែលសមស្រប ដែលនឹងត្រូវបានធ្វើឡើងដោយសហចៅក្រមស៊ើបអង្កេត មុនពេលធ្វើសេចក្តីសម្រេចអំពីថាតើបុគ្គលណាមួយចំនួនគួរត្រូវបានធ្វើការចោទប្រកាន់ និងបញ្ជូនទៅជំនុំជំរះដែរឬទេ?។

## សេចក្តីជូនដំណឹងដល់ដើមបណ្តឹងរដ្ឋប្បវេណីដែលមានសក្តានុពលទាំងឡាយនៅក្នុងសំណុំរឿងលេខ០០៣

អនុលោមតាមវិធាន២៣ស្ទួននៃវិធានផ្ទៃក្នុង បុគ្គលទាំងឡាយណាដែលមានបំណងចង់សុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនៅក្នុងសំណុំរឿងលេខ០០៣ ត្រូវដាក់ពាក្យសុំជាលាយលក្សណ៍អក្សរយ៉ាងយូរដប់ប្រាំ (១៥) ថ្ងៃបន្ទាប់ពីកាលបរិច្ឆេទដែលសហចៅក្រមស៊ើបអង្កេតជូនដំណឹងដល់សហព្រះរាជអាជ្ញាថា ខ្លួនយល់ឃើញថាការស៊ើបសួរត្រូវបានបញ្ចប់។ អនុលោមតាមបទប្បញ្ញត្តិច្បាប់ដែលពាក់ព័ន្ធ សហព្រះរាជអាជ្ញាអន្តរជាតិយល់ឃើញថា កាលបរិច្ឆេទកំណត់សំរាប់ការដាក់ពាក្យសុំរបស់ដើមបណ្តឹងរដ្ឋប្បវេណីឥឡូវនេះគឺត្រូវចំថ្ងៃពុធទី១៨ ខែឧសភា ឆ្នាំ២០១១ វេលាម៉ោង៤រសៀល។

ដោយពិនិត្យឃើញថា ទីតាំងនៃឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្រោមកិច្ចស៊ើបសួរកាលពីមុនមកមិនទាន់ត្រូវបានផ្សព្វផ្សាយឲ្យដឹងជាសាធារណៈនៅឡើយនោះ សហព្រះរាជអាជ្ញាអន្តរជាតិ នឹងស្នើសុំដល់ សហចៅក្រមស៊ើបអង្កេត សុំឲ្យពន្យាពេលនៃកាលបរិច្ឆេទកំណត់ចំនួន៦សប្តាហ៍បន្ថែមទៀត ដើម្បីនឹងអនុញ្ញាតឲ្យជនរងគ្រោះដាក់ពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី។ ប៉ុន្តែបច្ចុប្បន្ននេះ ការធានាតែមួយគត់ដែលថាពាក្យសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីនឹងត្រូវបានសហចៅក្រមស៊ើបអង្កេតទទួលធ្វើការពិនិត្យពិចារណានោះ គឺមានតែត្រូវដាក់ពាក្យសុំនោះឲ្យបានមុនថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០០១១ នៅវេលាម៉ោង ៤រសៀលតែប៉ុណ្ណោះ។ ក្នុងករណីបើសិនជា សហចៅក្រមស៊ើបអង្កេត ពន្យាពេលនៃការបរិច្ឆេទកំណត់នោះ និងមានធ្វើសេចក្តីជូនដំណឹងដល់សាធារណៈជន។

តាមវិធាន២៣ស្ទួននៃវិធានផ្ទៃក្នុង អវតក និងមាត្រា៣.២ នៃសេចក្តីណែនាំអនុវត្តស្តីពីការចូលរួមរបស់ជនរងជនរងគ្រោះណាម្នាក់ដែលត្រូវបានកំណត់ថាគឺជារូបវន្តបុគ្គល ឬនីតិបុគ្គលដែលបានទទួលរងនូវព្យសនកម្មដោយការខូចខាតខាងរាងកាយ សម្ភារៈនិងខាងផ្លូវចិត្ត ដែលជាផលវិបាកផ្ទាល់ដោយសារឧក្រិដ្ឋកម្មយ៉ាងហោចណាស់ក៏មួយក្នុងចំណោមឧក្រិដ្ឋកម្មទាំងឡាយដែលបានចោទប្រកាន់។

ជនរងគ្រោះទាំងឡាយដែលមានគោលបំណងចង់ដាក់ពាក្យសុំ ត្រូវទំនាក់ទំនងមកអង្គភាពគាំពារជនរងគ្រោះ នៃ អវតក ដើម្បីបំពេញបែបបទក្នុងទម្រង់សំរាប់បំពេញពត៏មានស្តីពីជនរងគ្រោះ ហើយដាក់មកនៅក្នុងសប្តាហ៍នេះ ។ ការិយាល័យនេះបើកធ្វើការពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ លើកលែងតែថ្ងៃបុណ្យជាតិ។ អាស័យដ្ឋាន៖

**<u>អង្គភាពគាំពារជនរងគ្រោះនៃអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា</u>**

**ផ្លូវជាតិលេខ៤,**
**សង្កាត់ចោមចៅ, ខណ្ឌដង្កោ,**
**ប្រអប់សំបុត្រលេខ ៧១,**
**រាជធានីភ្នំពេញ,   ព្រះរាជាណាចក្រកម្ពុជា**

ការិយាល័យប្រចាំនៅភ្នំពេញ៖
**ផ្ទះលេខ ៦ក,**
**ផ្លូវលេខ២១,  សង្កាត់ទន្លេបាសាក់ I,  ខណ្ឌចំការមន**
**រាជធានីភ្នំពេញ,  ព្រះរាជាណាចក្រកម្ពុជា**

**ទូរស័ព្ទលេខ ៖  ០២៣ ២១៤ ២៩១ ។  ឬលេខ ០៩៧ ៧៤២ ៤២១៨ (helpline)**

## សេចក្តីជូនដំណឹងដល់អ្នកដើមបណ្តឹងដែលមានសក្តានុពលទាំងឡាយនៅក្នុងសំណុំរឿងលេខ០០៣

បុគ្គលទាំងឡាយណាដែលមានព័ត៌មានស្តីពីឧក្រិដ្ឋកម្មដែលកំពុងស្ថិតនៅក្រោមកិច្ចស៊ើបសួរ អាចដាក់ជូនទូវព័ត៌មានទាំងនោះទៅ សហព្រះរាជអាជ្ញា បាន ។ តាមវិធាន៤៩.២ នៃវិធានផ្ទៃក្នុង ពាក្យបណ្តឹង ឬព័ត៌មានទាំងឡាយអាចដាក់ជូនទៅ សហព្រះរាជអាជ្ញា ដោយបុគ្គលណាម្នាក់ អង្គការ ឬតាមប្រភពផ្សេងទៀត ជាជនដែលបានដឹងឮជាសាក្សី ឬជាជនរងគ្រោះនៃបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់ ឬជាជនដែលបានដឹងអំពីបទឧក្រិដ្ឋដែលត្រូវចោទប្រកាន់នោះ។

វិធាន៤៩នៃវិធានផ្ទៃក្នុង ប្រគល់ភារកិច្ចដល់ សហព្រះរាជអាជ្ញា ក្នុងការធ្វើការវាយតម្លៃលើពាក្យបណ្តឹង ឬព័ត៌មានទាំងឡាយដែលចោទប្រកាន់អំពីការប្រព្រឹត្តបទឧក្រិដ្ឋកម្មនានាដែលស្ថិតនៅក្នុងយុត្តាធិការរបស់ អវតក ។ នៅពេលដែល សហព្រះរាជអាជ្ញា បានទទួលពាក្យបណ្តឹង ឬព័ត៌មានដែលទាក់ទងទៅនឹងកិច្ចស៊ើបសួររបស់តុលាការដែលកំពុងតែដំណើរការ សហព្រះរាជអាជ្ញា អាចបញ្ជូនពាក្យបណ្តឹងឬព័ត៌មានទាំងនេះទៅឲ្យសហចៅក្រមស៊ើបអង្កេត ដើម្បីដាក់បញ្ចូលទៅក្នុងសំណុំរឿងធ្វើជាភស្តុតាង។ ពាក្យបណ្តឹងឬព័ត៌មានទាំងឡាយអាចដាក់ជូនតាមរយៈអង្គភាពគាំពារជនរងគ្រោះ ឬទៅ សហព្រះរាជអាជ្ញា ដោយផ្ទាល់។ នៅពេលដែលមិនមានការបញ្ជាក់អំពីកាលបរិច្ឆេទកំណត់ច្បាស់លាស់សម្រាប់ការដាក់ពាក្យបណ្តឹងទេនោះ សហព្រះរាជអាជ្ញាអន្តរជាតិ សូមលើកទឹកចិត្តដល់ជនរងគ្រោះនិងសាក្សីទាំងឡាយដែលមានបំណងចង់ធ្វើពាក្យបណ្តឹងអំពីឧក្រិដ្ឋកម្មទាំងឡាយដូចដែលបានរៀបរាប់នៅក្នុងសំណុំរឿងលេខ០០៣ ដើម្បីឲ្យដាក់ពាក្យបណ្តឹងឲ្យបានឆាប់រហ័សបំផុតតាមតែអាចធ្វើទៅបាន៕

---